ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៣៤៦ សហវ.ប្រក

# ប្រកាស
# ស្តីពី
# ការអនុញ្ញាតឱ្យយកធនធានពីគយមុនពេលបញ្ចប់ការបំពេញបែបបទបញ្ចេញធនធានពីគយ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១១២ សហវ.ប្រក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីនិមុត្តិធានា
- បានឃើញប្រកាសលេខ ៧៣៤ សហវ.ប្រក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីនីតិវិធីគយពិសេសសម្រាប់អនុវត្តក្នុងតំបន់សេដ្ឋកិច្ចពិសេស


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញប្រកាសលេខ ៥៧០ សហវ.ប្រក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១០ ស្តីពីនីតិវិធីតវ៉ាប្រឆាំងកំណត់ហេតុគយ
- បានឃើញប្រកាសលេខ ៥៧១ សហវ.ប្រក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១០ ស្តីពីនីតិវិធីនៃការបង់ពន្ធនិងអាករលើទំនិញនាំចេញ និងទំនិញនាំចូល
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

ប្រកាសនេះកំណត់អំពីលក្ខខណ្ឌ និងនីតិវិធីនៃការអនុញ្ញាតឱ្យយកទំនិញពីគយមុនពេលបញ្ចប់ការបំពេញបែបបទបញ្ចេញទំនិញពីគយ ឬការជិពាក់បែបបទគយ ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តស្របតាមបញ្ញត្តិមាត្រា១៤ នៃច្បាប់ស្តីពីគយ។

**ប្រការ២.-**

ទំនិញដែលអាចត្រូវបានអនុញ្ញាតឱ្យយកពីគយ មុនពេលបញ្ចប់ការបំពេញបែបបទបញ្ចេញទំនិញពីគយ រួមមាន÷

- ទំនិញនាំចូលរបស់ក្រសួង-ស្ថាប័នរដ្ឋ
- ទំនិញនាំចូលក្នុងក្របខ័ណ្ឌហិរញ្ញប្បទាន និងទំនិញនាំចូលរបស់គម្រោងវិនិយោគសាធារណៈ ដែលនឹងត្រូវទទួលបានការអនុម័តពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និង/ឬ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងការដាក់ពន្ធនិងអាករជាបន្ទុករបស់រដ្ឋ
- ទំនិញនាំចូលជាសម្ភារៈសាងសង់ បរិក្ខារសំណង់ សម្ភារៈបរិក្ខារផលិតកម្ម និងធាតុចូលផលិតកម្មរបស់គម្រោងវិនិយោគឯកជននានា
- ទំនិញនាំចូលជាកម្មវត្ថុនៃការបង់ពន្ធអាករដែលមានតម្រូវការបន្ទាន់ឬចាំបាច់ ប៉ុន្តែពុំទាន់មានការឯកភាពគ្នាលើទិដ្ឋភាពបច្ចេកទេសគយ ដូចជា តម្លៃគិតពន្ធគយ ចំណាត់ថ្នាក់ទំនិញ ឬដើមកំណើតទំនិញជាដើម
- ទំនិញដែលត្រូវរង់ចាំសេចក្តីសម្រេចលើការតវ៉ា ឬទំនិញដែលត្រូវបានឃាត់ទុកបណ្តោះអាសន្ន និង
- ទំនិញផ្សេងទៀត ដែលទទួលបានការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៣.-**

លើកលែងតែមានការសម្រេចដោយឡែកពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ការអនុញ្ញាតឱ្យយកទំនិញពីគយមុនពេលបញ្ចប់ការបំពេញបែបបទបញ្ចេញទំនិញពីគយ មិនត្រូវបានអនុញ្ញាតចំពោះការនាំចូលទំនិញមួយចំនួនរួមមាន÷

- ទំនិញហាមឃាត់និងជាប់កម្រិតកំណត់ ដែលមិនទាន់ទទួលបានការអនុញ្ញាតឱ្យនាំចូលពីក្រសួង-ស្ថាប័នមានសមត្ថកិច្ច និង
- ប្រេងឥន្ធនៈ។

**ប្រការ ៤.-**

ដើម្បីទទួលបានការអនុញ្ញាតឱ្យយកទំនិញពីគយមុនពេលបញ្ចប់ការបំពេញបែបបទបញ្ចេញទំនិញពីគយ ម្ចាស់ទំនិញត្រូវស្នើសុំជាលាយលក្ខណ៍អក្សរនៅអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។ ការស្នើសុំនេះអាចតម្រូវឱ្យតម្កល់និមុត្តិធានាជាសាច់ប្រាក់ ឬជាទម្រង់ផ្សេងទៀត តាមការសម្រេចរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ស្របតាមបទប្បញ្ញត្តិនៃប្រកាសស្តីពីនិមុត្តិធានា។

ដោយឡែក ការស្នើសុំការអនុញ្ញាតឱ្យយកទំនិញពីគយមុនពេលបញ្ចប់ការបំពេញបែបបទបញ្ចេញទំនិញពីគយ របស់អ្នកអភិវឌ្ឍន៍តំបន់ និងវិនិយោគិនក្នុងតំបន់សេដ្ឋកិច្ចពិសេស ត្រូវអនុវត្តតាមនីតិវិធីគយពិសេសសម្រាប់អនុវត្តក្នុងតំបន់សេដ្ឋកិច្ចពិសេស។

**ប្រការ ៥.-**

ការអនុញ្ញាតឱ្យយកទំនិញពីគយមុនពេលបញ្ចប់ការបំពេញបែបបទបញ្ចេញទំនិញពីគយ ត្រូវបានផ្តល់ជូនរយៈពេលយ៉ាងយូរ ៩០ (កៅសិប) ថ្ងៃ ក្រោយពេលទទួលទំនិញ ឬគិតចាប់ពីថ្ងៃចុះបញ្ជិកាប្រតិវេទន៍គយ ដើម្បីម្ចាស់ទំនិញបញ្ចប់ការបំពេញបែបបទបញ្ចេញទំនិញពីគយ។

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាអាចពន្យាររយៈពេលនេះបានចំនួន ២ (ពីរ) លើក នៃរយៈពេលដែលត្រូវបានអនុញ្ញាតដំបូង តាមការស្នើសុំជាលាយលក្ខណ៍អក្សររបស់ម្ចាស់ទំនិញ ក្នុងករណីមានហេតុផលសមស្រប តាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។ ការពន្យាររយៈពេលបន្ថែមទៀត ត្រូវមានការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ ៦.-**

ក្នុងករណីមិនបានបញ្ចប់ការបំពេញបែបបទបញ្ចេញទំនិញពីគយតាមកាលកំណត់ ម្ចាស់ទំនិញត្រូវទទួលរងការពិន័យរដ្ឋបាល ស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីគយ។

ក្នុងករណីមិនបានបញ្ចប់ការបំពេញបែបបទបញ្ចេញទំនិញពីគយលើសកាលកំណត់ ៩០ (កៅសិប) ថ្ងៃ គិតចាប់ពីរយៈពេលនៃការអនុញ្ញាតចុងក្រោយ ម្ចាស់ទំនិញត្រូវទទួលរងការពិន័យរដ្ឋបាល និងទោសទណ្ឌផ្សេងទៀត ស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីគយ និងច្បាប់ផ្សេងទៀត ហើយនិមុត្តិធានាត្រូវបង្វែរចូលថវិកាជាតិ បើសិនជាមាន។

**ប្រការ ៧.-**

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ត្រូវដោះបន្ទុកនិមុត្តិធានាឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ក្រោយពេលពិនិត្យឃើញថាកាតព្វកិច្ចនានានៃនិមុត្តិធានាត្រូវបានបំពេញរួចរាល់។

**ប្រការ៨.-**

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អាចចេញសេចក្តីណែនាំបន្ថែមសម្រាប់ការគ្រប់គ្រង និងការតាមដាន ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តការអនុញ្ញាតឱ្យយកទំនិញពីគយ មុនពេលបញ្ចប់ការបំពេញបែបបទបញ្ចេញទំនិញពីគយ។

**ប្រការ៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១០.-**

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកនៃវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគ្រប់ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ១៣កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២២ ខែ មិថុនា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-សភាពាណិជ្ជកម្មកម្ពុជា
-ដូចប្រការ ១០
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ